# Manulife Premier

## Frequently Asked Questions

Khmer and English

INTERNAL

| No | Questions | Section |
|---|---|---|
| 1 | **តើ Manulife Premier ជាអ្វី?**<br>What is Manulife Premier? | |
| 2 | **តើហេតុអ្វីខ្ញុំគួរទិញគម្រោងធានារ៉ាប់រងនេះ?**<br>Why should I consider buying this product? | |
| 3 | តើ **Manulife Premier មានប៉ុន្មានជម្រើសកញ្ចប់? ហើយជម្រើសកញ្ចប់នីមួយៗមានអត្ថប្រយោជន៍អ្វីខ្លះ?**<br>How many package of this product? What are the benefits of this product? | |
| 4 | **តើគម្រោង Manulife Premier កញ្ចប់ Health មានអត្ថប្រយោជន៍អ្វីខ្លះ?**<br>What are the benefit of Manulife Premier Health Package? | **ផលិតផល និងអត្ថប្រយោជន៍**<br>Product and Benefit |
| 5 | **តើគម្រោង Manulife Premier កញ្ចប់ Protect មានអត្ថប្រយោជន៍អ្វីខ្លះ?**<br>What are the benefit of Manulife Premier Protect Package? | |
| 6 | **តើគម្រោង Manulife Premier កញ្ចប់ Save មានអត្ថប្រយោជន៍អ្វីខ្លះ?**<br>What are the benefit of Manulife Premier Save Package? | |
| 7 | **តើគម្រោង Manulife Premier នេះ ផ្តល់ការការពាររយៈពេលប៉ុន្មានឆ្នាំ? តើខ្ញុំត្រូវបង់បុព្វលាភធានារ៉ាប់រងរយៈពេលប៉ុន្មាន?**<br>How long is the coverage period? How long do I have to pay the premium? | |
| 8 | **តើក្រុមហ៊ុនតម្រូវឱ្យអតិថិជនពិនិត្យសុខភាពដែរ ឬ ទេ សម្រាប់ គម្រោង Manulife Premier?**<br>For Manulife Premier, does the company require customers to do a medical check up? | **លក្ខខណ្ឌតម្រូវ**<br>Eligibility |
| 9 | **តើនរណាខ្លះអាចទទួលបានការធានាពី Manulife Premier?**<br>Who is eligible for Manulife Premier? | |
| 10 | **តើខ្ញុំត្រូវបង់បុព្វលាភធានារ៉ាប់រងចំនួនប៉ុន្មាន?**<br>How much do I have to pay the premium? | **បុព្វលាភធានារ៉ាប់រង**<br>Premium |
| 11 | **តើខ្ញុំអាចទទួលបានទឹកប្រាក់ដែលខ្ញុំបានបង់ត្រលប់មកវិញដែរ ឬទេ ប្រសិនបើខ្ញុំបញ្ចប់បណ្ណសន្យារ៉ាប់រងមុនកាលកំណត់?**<br>Will I get my money back if I decide to terminate the Policy before its maturity date? | |
| 12 | **តើខ្ញុំអាចទាមទារសំណងធានារ៉ាប់រងរបស់ខ្ញុំតាមវិធីណា?**<br>How do I claim my benefit? | **ការទាមទារសំណង**<br>Claim |
| 13 | **តើដំណើរការទាមទារសំណង ត្រូវចំណាយរយៈពេលប៉ុន្មានថ្ងៃ?**<br>How long does the claim process take? | |

## តើ Manulife Premier គឺជាអ្វី?
## What is Manulife Premier?

Manulife Premier ត្រូវបានបង្កើតឡើងជាពិសេស ដើម្បីផ្តល់ការការពារយ៉ាងទូលំទូលាយទៅលើ ជំងឺធ្ងន់ធ្ងរ មរណភាពនិងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ និងមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ។ ផលិតផលនេះផ្តល់ជម្រើស 3 កញ្ចប់ផ្សេងគ្នា ដើម្បីឱ្យសមស្របតាមតម្រូវការការការពាររបស់លោកអ្នក។ បន្ថែមពីនេះម្ចាស់បណ្ណសន្យារ៉ាប់រង នឹងទទួលបានអត្ថប្រយោជន៍លើការសន្សំវិញ នៅកាលបរិច្ឆេទទូទាត់អត្ថប្រយោជន៍ ជាទឹកប្រាក់សរុប ឬជាដំណាក់កាល។

Manulife Premier is a life insurance plan specifically designed to provide comprehensive protection against Critical Illness, Death, and Permanent Disability resulting from either accidental or non-accidental events. It offers flexible 3 package options to suit your protection needs. In addition, the plan includes a savings benefit payable to the policyowner at the end of the policy term if no claim has been made, either as a lump-sum payout or in installments.

Manulife

## តើហេតុអ្វីខ្ញុំគួរទិញគម្រោងធានារ៉ាប់រងនេះ?
## Why should I consider buying this product?

យើងខ្ញុំដឹងថាលោកអ្នកពិតជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីកសាងអាជីពដ៏ជោគជ័យ អាជីវកម្មដ៏រឹងមាំ និងអនាគតដ៏ប្រសើរ សម្រាប់មនុស្សជាទីស្រលាញ់។ ទោះជាយ៉ាងណាក៏ដោយ ហេតុការណ៍ដែលមិនបានរំពឹងទុកមួយចំនួនអាចផ្លាស់ប្តូរស្ថានភាពនោះបានយ៉ាងឆាប់រហ័ស។ ហេតុការណ៍ទាំងនោះអាចបង្កផលប៉ះពាល់ដល់ សុខភាព ជីវិត និងទ្រព្យសម្បត្តិរបស់លោកអ្នក ហើយប្រសិនបើថ្ងៃណាមួយលោកអ្នកលែងនៅទីនេះទៀត តើមនុស្សដែលពឹងផ្អែកលើអ្នកនឹងក្លាយជាយ៉ាងណា?

ដើម្បីអាចជួយលោកអ្នកផ្តោតលើការពង្រីកសក្តានុពល និងបន្តដំណើរទៅមុខប្រកបដោយទំនុកចិត្ត ជាមួយ **Manulife Premier** លោកអ្នកនឹងទទួលបានការការពារយ៉ាងទូលំទូលាយ ជាមួយជម្រើសកញ្ចប់ដែលស័ក្តិសមបំផុតជាមួយនឹងគោលដៅហិរញ្ញវត្ថុរបស់លោកអ្នក។ ទោះជាជួបប្រទះការប្រែប្រួល ឬស្ថានភាពមិនបានរំពឹងទុកក៏ដោយ លោកអ្នកនៅតែអាចបន្តដំណើរជីវិត ដឹកនាំគ្រួសារ និងអាជីវកម្មទៅមុខបានដោយទំនុកចិត្ត និងក្តីសង្ឃឹមសម្រាប់អនាគត។

We understand that you have worked very hard build a successful career and a strong business, and a secure future for the people who matter to you. However, even unexpected events can quickly change circumstances. Such events can affect your health, life, and wealth—and if you were no longer here, what would happen to the people who depend on you?

To help you move forward with confidence, **Manulife Premier** offers a comprehensive protection plan with Premier packages designed to suit your financial objectives. You can continue to lead your life, protect your family, and grow your business with confidence and hope for the future. Even when facing change or unexpected circumstances.

Manulife

# តើ Manulife Premier មានប៉ុន្មានជម្រើសកញ្ចប់? ហើយជម្រើសកញ្ចប់នីមួយៗមានអត្ថប្រយោជន៍អ្វីខ្លះ?
## How many package of this product? What are the benefits of this product?

**Manulife Premier** មាន 3 ជម្រើសកញ្ចប់សម្រាប់តម្រូវតាមគោលដៅហិរញ្ញវត្ថុរបស់លោកអ្នក៖
Manulife Premier has 3 package:

| ផលិតផលធានារ៉ាប់រង | Manulife Premier Health | Manulife Premier Protect | Manulife Premier Save |
|---|---|---|---|
| **មូលដ្ឋាន** | **អត្ថប្រយោជន៍ការការពារអាយុជីវិត និងការសន្សំ៖**<br>• អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាល ឬមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ)<br>• អត្ថប្រយោជន៍លើការសន្សំ*<br>• អត្ថប្រយោជន៍លើការបោះបង់បណ្ណសន្យារ៉ាប់រង | **អត្ថប្រយោជន៍ការការពារអាយុជីវិត និងការសន្សំ៖**<br>• អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាល ឬមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ)<br>• អត្ថប្រយោជន៍លើការសន្សំ*<br>• អត្ថប្រយោជន៍លើការបោះបង់បណ្ណសន្យារ៉ាប់រង<br><br>**អត្ថប្រយោជន៍បង្កើនការការពារអាយុជីវិត**<br>• អត្ថប្រយោជន៍បន្ថែមលើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាល ឬមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ) | **អត្ថប្រយោជន៍ការការពារអាយុជីវិត និងការសន្សំ៖**<br>• អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាល ឬមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ)<br>• អត្ថប្រយោជន៍លើការសន្សំ*<br>• អត្ថប្រយោជន៍លើការបោះបង់បណ្ណសន្យារ៉ាប់រង |
| **បន្ថែម** | **អត្ថប្រយោជន៍បន្ថែមការការពារ និងព្យាបាលជំងឺធ្ងន់ធ្ងរ៖**<br>• អត្ថប្រយោជន៍បន្ថែមលើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាល ឬមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ<br>• អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់<br>• អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរកម្រិតដំបូង<br>• អត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ | | |

| Plan Type | Manulife Premier Health | Manulife Premier Protect | Manulife Premier Save |
|---|---|---|---|
| **Base** | **Life Protection and Saving Benefits:**<br>• Death and Total Permanent Disability Benefit<br>• Savings Benefit*<br>• Surrender Benefit | **Life Protection and Saving Benefits:**<br>• Death and Total Permanent Disability Benefit<br>• Savings Benefit*<br>• Surrender Benefit<br><br>**Life Protection Booster Benefits:**<br>• Additional Death and Total Permanent Disability Benefit | **Life Protection and Saving Benefits:**<br>• Death and Total Permanent Disability Benefit<br>• Savings Benefit*<br>• Surrender Benefit |
| **Rider** | **Additional Protection and Critical Illness Benefits:**<br>• Additional Death and Total Permanent Disability Benefit<br>• Early-stage Critical Illnesses<br>• Major-stage Critical Illnesses<br>• Waiver of Premium Benefit on Major-Stage Critical Illnesses | | |

*លោកអ្នកអាចជ្រើសរើសទទួលយកនូវអត្ថប្រយោជន៍លើការសន្សំ ការទូទាត់ជាទឹកប្រាក់សរុប ឬការទូទាត់ជា 5 ដំណាក់កាល នៅចុងឆ្នាំនៃបណ្ណសន្យារ៉ាប់រងនីមួយៗ ចាប់ពី 4 ឆ្នាំមុនកាលបរិច្ឆេទដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង។
* You can choose to receive Saving Benefit in a Lump Sum or five (5) Installments at the end of every policy year starting at 4 years prior to Policy Maturity Date..

## តើគម្រោង Manulife Premier កញ្ចប់ Health មានអត្ថប្រយោជន៍អ្វីខ្លះ?
## What are the benefit of Manulife Premier Health Package?

Manulife Premier កញ្ចប់ **Health** ត្រូវបានបង្កើតឡើងផ្តោតលើការការពារលើជំងឺធ្ងន់ធ្ងរ មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។

Manulife Premier កញ្ចប់ Health មានអត្ថប្រយោជន៍ដូចជា៖

**ផលិតផលធានារ៉ាប់រងមូលដ្ឋាន**

អត្ថប្រយោជន៍ការការពារអាយុជីវិត និងការសន្សំ៖

- អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាល ឬមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ)
- អត្ថប្រយោជន៍លើការសន្សំ
- អត្ថប្រយោជន៍លើការបោះបង់បណ្ណសន្យារ៉ាប់រង

**ផលិតផលធានារ៉ាប់រងបន្ថែម**

**អត្ថប្រយោជន៍បន្ថែមការការពារ និងព្យាបាលជំងឺធ្ងន់ធ្ងរ**

- អត្ថប្រយោជន៍បន្ថែមលើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាល ឬទីមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ
- អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់
- អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរកម្រិតដំបូង
- អត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រងលើជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់

សម្គាល់៖ អត្ថប្រយោជន៍បន្ថែមការការពារ និងព្យាបាលជំងឺធ្ងន់ធ្ងរ នេះមានតែនៅ Manulife Premier កញ្ចប់ Health តែប៉ុណ្ណោះ។

សូមទាក់ទងមកកាន់បុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងរបស់មេនូឡាយហ្វ៍ ដើម្បីកំណត់ទឹកប្រាក់ធានារ៉ាប់រងដែលស័ក្តិសមជាមួយតម្រូវការរបស់លោកអ្នក។

Manulife Premier **Health** is specifically designed to provide protection against critical illness, death, and total and permanent disability.

Manulife Premier Health with the following benefits:

**Base**

**Life Protection and Saving Benefits:**

- Death and Total Permanent Disability Benefit
- Savings Benefit
- Surrender Benefit

**Rider**

**Additional Protection and Critical Illness Benefits**

- Additional Death and Total Permanent Disability Benefit
- Early-stage Critical Illnesses
- Major-stage Critical Illnesses
- Waiver of Premium Benefit on Major-Stage Critical Illnesses

Note: Additional Protection and Critical Illness Benefits is applicable only for Manulife Premier Health

Please reach out to our Insurance Specialist/Agent to determine the right face amount for you.

## តើគម្រោង Manulife Premier កញ្ចប់ Protect មានអត្ថប្រយោជន៍អ្វីខ្លះ?
## What are the benefit of Manulife Premier Protect Package?

Manulife Premier កញ្ចប់ Protect ត្រូវបានបង្កើតឡើងផ្ដោតលើការការពារខ្ពស់ លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។

Manulife Premier កញ្ចប់ Protect មានអត្ថប្រយោជន៍ដូចជា៖

**ផលិតផលធានារ៉ាប់រងមូលដ្ឋាន**

**អត្ថប្រយោជន៍ការការពារអាយុជីវិត និងការសន្សំ៖**

- អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្ដាល ឬមិនបណ្ដាលមកពីគ្រោះថ្នាក់ចៃដន្យ)
- អត្ថប្រយោជន៍លើការសន្សំ
- អត្ថប្រយោជន៍លើការបោះបង់បណ្ណសន្យារ៉ាប់រង

**អត្ថប្រយោជន៍បង្កើនការការពារអាយុជីវិត**

- អត្ថប្រយោជន៍បន្ថែមលើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្ដាល ឬមិនបណ្ដាលមកពីគ្រោះថ្នាក់ចៃដន្យ)

សូមទាក់ទងមកកាន់បុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងរបស់មេនូឡាយហ្វ៍ ដើម្បីកំណត់ទឹកប្រាក់ធានារ៉ាប់រងដែលស័ក្តិសមជាមួយតម្រូវការរបស់លោកអ្នក។

Manulife Premier Protect is specifically designed to provide higher protection for death and total and permanent disability.

Manulife Premier Protect with the following benefits:

**Base**

**Life Protection and Saving Benefits:**

- Death and Total Permanent Disability Benefit
- Savings Benefit
- Surrender Benefit

**Life Protection Booster Benefits:**

Additional Death and Total Permanent Disability Benefit

Please reach out to our Insurance Specialist/Agent to determine the right face amount for you.

## តើគម្រោង Manulife Premier កញ្ចប់ Save មានអត្ថប្រយោជន៍អ្វីខ្លះ?
## What are the benefit of Manulife Premier Save Package?

Manulife Premier កញ្ចប់ Save ត្រូវបានបង្កើតឡើង សម្រាប់លោកអ្នកមានគោលដៅហិរញ្ញវត្ថុ ទឹកប្រាក់សន្សំខ្ពស់ត្រលប់ទៅវិញ និងទទួលបានការការពារលើ មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។

Manulife Premier កញ្ចប់ Save មានអត្ថប្រយោជន៍ដូចជា៖

**ផលិតផលធានារ៉ាប់រងមូលដ្ឋាន**

អត្ថប្រយោជន៍ការការពារអាយុជីវិត និងការសន្សំ៖

- អត្ថប្រយោជន៍លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាល ឬមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ)
- អត្ថប្រយោជន៍លើការសន្សំ
- អត្ថប្រយោជន៍លើការបោះបង់បណ្ណសន្យារ៉ាប់រង

សូមទាក់ទងមកកាន់បុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងរបស់មេនូឡាយហ្វ៍ ដើម្បីកំណត់ទឹកប្រាក់ធានារ៉ាប់រង ដែលស័ក្តិសមជាមួយតម្រូវការរបស់លោកអ្នក។

Manulife Premier Save is specifically designed for those who are looking for higher returns on savings benefits along with protection for death and permanent disability

Manulife Premier Save with the following benefits:

**Base**

**Life Protection and Saving Benefits:**

- Death and Total Permanent Disability Benefit
- Savings Benefit
- Surrender Benefit

Please reach out to our Insurance Specialist/Agent to determine the right face amount for you.

## **តើគម្រោង** Manulife Premier **នេះ ផ្តល់ការពាររយៈពេលប៉ុន្មានឆ្នាំ? តើខ្ញុំត្រូវបង់បុព្វលាភធានារ៉ាប់រងរយៈពេលប៉ុន្មាន?**
## **How long is the coverage period? How long do I have to pay the premium?**

គម្រោង Manulife Premier ផ្តល់ការការពាររយៈពេល 10 ឆ្នាំ ឬ 15 ឆ្នាំ ហើយរយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រងមានចាប់ពី 5 ឆ្នាំ ដល់ 15 ឆ្នាំ ស្របតាមប្រភេទកញ្ចប់ដែលលោកអ្នកជ្រើសរើស៖

| **កញ្ចប់** | **Manulife Premier Health** | | **Manulife Premier Protect** | **Manulife Premier Save** |
|---|---|---|---|---|
| រយៈពេលនៃការធានារ៉ាប់រង | 10 ឆ្នាំ ឬ 15 ឆ្នាំ | | 10 ឆ្នាំ ឬ 15 ឆ្នាំ | 10 ឆ្នាំ ឬ 15 ឆ្នាំ |
| រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង | គម្រោងធានារ៉ាប់រងមូលដ្ឋាន | 5 ឆ្នាំ ឬ 10 ឆ្នាំ | 5 ឆ្នាំ ឬ 10 ឆ្នាំ | 5 ឆ្នាំ ឬ 10 ឆ្នាំ |
| | ផលិតផលធានារ៉ាប់រងបន្ថែម | 10 ឆ្នាំ ឬ 15 ឆ្នាំ តាមរយៈពេលនៃការធានារ៉ាប់រង | | |

Manulife Premier offers coverage terms of 10 or 15 years, with payment terms starting from 5 years up to 15 years depending on the package you choose:

| **Package** | **Manulife Premier Health** | | **Manulife Premier Protect** | **Manulife Premier Save** |
|---|---|---|---|---|
| Coverage Term | 10 or 15 years | | 10 or 15 years | 10 or 15 years |
| Payment Term | Base Plan | 5 or 10 years | 5 or 10 years | 5 or 10 years |
| | Rider Plan | 10 or 15 years, following coverage term | | |

## សម្រាប់ គម្រោង Manulife Premier តើក្រុមហ៊ុនតម្រូវឱ្យអតិថិជនពិនិត្យសុខភាពដែរ ឬទេ?
## For Manulife Premier, does the company require customers to do a medical check up?

លោកអ្នក អាចនឹងតម្រូវឱ្យធ្វើការពិនិត្យសុខភាព ដោយផ្អែកតាមទំហំទឹកប្រាក់ធានារ៉ាប់រង និងការវាយតម្លៃធានារ៉ាប់រងរបស់ក្រុមហ៊ុន។ សម្រាប់តម្រូវការពិនិត្យសុខភាព បុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងរបស់យើង នឹងជួយណែនាំ ព្រមទាំងសម្របសម្រួលរហូតដល់ដំណើរការនោះត្រូវបានបញ្ចប់ដោយរលូន។

Depending on your face amount, you may require doing health check based on our underwriting assessment. If any medical check-ups are needed, our Insurance Specialist/Agent will guide and support you throughout the process.

Manulife

## តើនរណាអាចទទួលបានការធានាពី Manulife Premier?
## Who is eligible for Manulife Premier?

លក្ខខណ្ឌក្នុងការទិញ៖ តាមកញ្ចប់នីមួយៗ

| **កញ្ចប់** | **Manulife Premier Health** | **Manulife Premier Protect** | **Manulife Premier Save** |
|---|---|---|---|
| រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង | 10 ឆ្នាំ ឬ 15 ឆ្នាំ | 5 ឆ្នាំ ឬ 10 ឆ្នាំ | |
| អាយុដែលទទួលបានការការពារ | ចាប់ពី 18 ឆ្នាំ ដល់ 60 ឆ្នាំ | ចាប់ពី 30 ថ្ងៃ ដល់ 60 ឆ្នាំ | ចាប់ពី 30 ថ្ងៃ ដល់ 60 ឆ្នាំ |

Purchase Eligibility: Base on the package

| **Package** | **Manulife Premier Health** | **Manulife Premier Protect** | **Manulife Premier Save** |
|---|---|---|---|
| Payment Term | 10 or 15 years | 5 or 10 years | |
| Age Eligibility | 18 to 60 Years Old | 30 days to 60 Years Old | 30 days to 60 Years Old |

Manulife

## តើខ្ញុំត្រូវបង់បុព្វលាភធានារ៉ាប់រងចំនួនប៉ុន្មាន?
## How much do I have to pay the premium?

ចំនួនបុព្វលាភធានារ៉ាប់រង ដែលត្រូវបង់អាស្រ័យលើចំនួនទឹកប្រាក់ធានារ៉ាប់រង (កញ្ចប់ “Health” កញ្ចប់ “Protect” ឬ កញ្ចប់ “Save” ) ដែលលោកអ្នកបានជ្រើសរើស។ សូមទាក់ទងមកក្រុមហ៊ុន ឬបុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រង សម្រាប់ការប្រឹក្សាលម្អិតពីកញ្ចប់ផលិតផលធានារ៉ាប់រង និងការទូទាត់បុព្វលាភធានារ៉ាប់រង។

The premium you need to pay depends on coverage amount and the protection package you choose (Health, Protect or Save package). Please discuss with our Insurance Specialist/Agent if you would like to learn more about the product packages and premium payment in details.

## តើខ្ញុំអាចទទួលបានទឹកប្រាក់ដែលខ្ញុំបានបង់ត្រលប់មកវិញដែរ ឬទេ ប្រសិនបើខ្ញុំបញ្ចប់បណ្ណសន្យារ៉ាប់រងមុនកាលកំណត់? Will I get my money back if I decide to stop the Policy coverage?

---

ក្រុមហ៊ុនមិនលើកទឹកចិត្តឱ្យលោកអ្នកធ្វើការបោះបង់បណ្ណសន្យារ៉ាប់រងមុនកាលបរិច្ឆេទដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រងឡើយ ពីព្រោះវានាំមកនូវការខាតបង់ពេលវេលា និងការការពារអត្ថប្រយោជន៍ដល់លោកអ្នក។

ក្នុងករណីលោកអ្នក (ក្នុងនាមជាម្ចាស់បណ្ណសន្យារ៉ាប់រង) ចង់បញ្ចប់ ឬបោះបង់បណ្ណសន្យារ៉ាប់រងមុនកាលកំណត់ ក្រុមហ៊ុន៖

- នឹងបង្វិលបុព្វលាភធានារ៉ាប់រងដែលបានបង់រួចសរុបជូនលោកអ្នកវិញ (ក្រោយដកថ្លៃសេវាកម្ម) ប្រសិនបើការស្នើសុំបោះបង់បណ្ណសន្យារ៉ាប់រងនេះកើតឡើងក្នុងអំឡុងពេល 21 ថ្ងៃបន្ទាប់ពីបណ្ណសន្យារ៉ាប់រងត្រូវបានផ្តល់ជូន។
- ប៉ុន្តែប្រសិនបើការស្នើសុំបោះបង់បណ្ណសន្យារ៉ាប់រងនេះកើតឡើងបន្ទាប់ពី 21 ថ្ងៃក្រោយពីបណ្ណសន្យារ៉ាប់រងត្រូវបានផ្តល់ជូន លោកអ្នកមិនអាចទទួលបានបុព្វលាភធានារ៉ាប់រងដែលបង់រួចត្រលប់ទៅវិញទេ។
- ប៉ុន្តែប្រសិនបើការស្នើសុំបោះបង់បណ្ណសន្យារ៉ាប់រងនេះកើតឡើងបន្ទាប់ពី ឆ្នាំទី 3 នៃបណ្ណសន្យារ៉ាប់រង លោកអ្នកអាចទទួលបានអត្ថប្រយោជន៍លើការបោះបង់បណ្ណសន្យារ៉ាប់រង

សូមពិភាក្សាជាមួយបុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រង ប្រសិនបើលោកអ្នកមានចម្ងល់ ឬមានការព្រួយបារម្ភណាមួយទាក់ទងនឹងបណ្ណសន្យារ៉ាប់រងលោកអ្នក។

The Company does not encourage you (Policyowner) to terminate the Policy before the expiration date as it may result in a loss in money and protection.
In case you (Policyowner) decide to terminate the Policy before its expiry date, the Company

- will return the total premiums paid to you (after service fee deduction), if the termination request is made within 21 days after the Policy is issued.
- will NOT return the total premiums paid to you, if the termination request is made more than 21 days after the Policy is issued.
- May provide surrender benefits , if the termination request is made after 3rd year of policy year.

Please consult with the Insurance Specialist/Agent if you have any questions or concerns regarding your Policy.

Manulife

## តើខ្ញុំអាចទាមទារសំណងធានារ៉ាប់រងរបស់ខ្ញុំតាមវិធីណា?
How do I claim my benefit?

ក្នុងអំឡុងពេលដ៏លំបាកនេះ យើងធានាថា យើងនៅទីនេះដើម្បីជួយលោកអ្នកគ្រប់វិធីដែលយើងអាចធ្វើបាន។ ដើម្បីទាមទារសំណងធានារ៉ាប់រងរបស់លោកអ្នក សូមអនុវត្តតាមជំហានដូចខាងក្រោម៖

- ឯកសារតម្រូវ៖ ឯកសារអត្តសញ្ញាណ បណ្ណសន្យារ៉ាប់រង និងពាក្យស្នើសុំទាមទារសំណងដែលពាក់ព័ន្ធ។
- ជូនដំណឹងទៅកាន់ក្រុមហ៊ុន មេនូឡាយហ្វ៍ អំពីព្រឹត្តិការណ៍សំណង ដើម្បីឱ្យយើងអាចណែនាំលោកអ្នកអំពីដំណើរការទាមទារសំណង៖
    - ទាក់ទងទៅបុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងរបស់លោកអ្នក
    - មកកាន់សាខាក្រុមហ៊ុន មេនូឡាយហ្វ៍ ដែលនៅជិតបំផុត
    - ទូរសព្ទមកកាន់លេខ៖ 1800-211-211 ឬអ៊ីមែល៖ claims_service_kh@manulife.com

- ដាក់ពាក្យស្នើសុំទាមទារសំណងរបស់លោកអ្នក៖ លោកអ្នកអាចដាក់ពាក្យស្នើសុំទាមទារសំណងធានរ៉ាប់រងតាមវិធីដូចខាងក្រោម៖
    - ទូរសព្ទ៖ ហៅមកយើងតាមលេខ 1800 211 211 សម្រាប់ជំនួយ។
    - អ៊ីមែល៖ ផ្ញើឯកសារ និងសំណួរទៅ claims_service_kh@manulife.com។
    - អនឡាញ៖ ចូលទៅកាន់គេហទំព័ររបស់យើង www.manulife.com.kh បន្ទាប់មកចូលទៅកាន់ “សេវាកម្ម” ហើយជ្រើសរើសយកពាក្យ “សេវាកម្មទាមទារសំណង” ស្វែងរកពាក្យ “ស្នើសុំទាមទារសំណងតាមប្រព័ន្ធអេឡិចត្រូនិក” រួចធ្វើតាមការណែនាំ។
    - ដោយផ្ទាល់ ឬតាមសំបុត្រ៖ លោកអ្នកក៏អាចផ្ញើឯកសារតាមសំបុត្រ ឬមកកាន់សាខាណាមួយរបស់យើង ដែលនៅជិតលោកអ្នក។

During these challenging times, we want to assure you that we are here to assist you in any way we can.
To claim your benefit, follow these steps:

- Gather Required Documents: Identification, policy details, and any relevant claim forms.
- Notify Manulife about claim events, so that we can guide you through the process :
    - Reach out to your insurance representative or
    - Come to nearest Manulife Branch or
    - Call to our hotline: 1800-211-211 or email: claims_service_kh@manulife.com.
- Submit Your Claim: You can submit your claim through the following methods:
    - Phone: Call us at 1800 211 211 for assistance.
    - Email: Send your documents and inquiries to claims_service_kh@manulife.com.
    - Online: Visit our website at www.manulife.com.kh, find “Services” tab, click on “File a claim” and then follow the instruction.
    - In-Person or Mail: You can also send your documents by mail or visit one of our branches if that’s more convenient.

Manulife

## តើដំណើរការទាមទារសំណង ត្រូវចំណាយរយៈពេលប៉ុន្មានថ្ងៃ?
## How long does the claim process take?

ក្រុមហ៊ុន នឹងឆ្លើយតបទៅអ្នកទាមទារសំណងធានារ៉ាប់រងអំពីសេចក្តីសម្រេចលើសំណើទាមទារសំណងធានារ៉ាប់រងជាលាយលក្ខណ៍អក្សរក្នុងរយៈពេលដប់ប្រាំ (15) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុនបានទទួលសំណើសុំទាមទារសំណង និងឯកសារតម្រូវគ្រប់គ្រាន់ ឬ តាមការកំណត់ដោយច្បាប់ជាធរមាន។

The Company shall respond in writing to the claimant(s) on claim decision within fifteen (15) working days from the date the claim is submitted. This is on the promise that the Company has received the document(s)/report(s) or as required by the law or regulations in force at the time of claim.

Manulife

Manulife